# ស្ថានីយផូស៊ីលសត្វសមុទ្រភ្នំទាក់ទ្រាំង ខេត្តបាត់ដំបង

ភ្នំទាក់ទ្រាំង មានទីតាំងភូមិសាស្ត្រស្ថិតនៅឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង (រូបលេខ១)។ ភ្នំនេះគេហៅខ្លះថាភ្នំល្អាងស្លាន ដែលជាស្ថានីយបុរេប្រវត្តិសាស្ត្រដ៏ចំណាស់មួយនៃប្រទេស កម្ពុជា ដែលត្រូវបានសិក្សាតាំងពីសម័យបារាំង និងបានបន្តសិក្សាដោយអ្នកបុរាណវិទ្យាខ្មែរក្នុងពេលបច្ចុប្បន្នផងដែរ (រូបលេខ២)។ ភ្នំទាក់ទ្រាំងត្រូវបានរាជរដ្ឋាភិបាលដាក់ជាតំបន់បេតិកភណ្ឌធម្មជាតិ ដោយអនុក្រឹត្យលេខ ០៦៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមាន ៧៩,៨២ហិចតា។[១] ក្រុមការងារសិក្សាផូស៊ីលនៃនាយកដ្ឋានតំបន់បេតិកភណ្ឌ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន បានទៅសិក្សាបឋមនៅតំបន់ភ្នំទាក់ទ្រាំង និងភ្នំនៅជាប់នោះផងដែរ កាលពីឆ្នាំ២០២០កន្លងមក(រូបលេខ៣)។[២]

តំបន់ភ្នំទាក់ទ្រាំងជាប្រភេទភ្នំថ្មកំបោរ មានអតីតកាលជាសមុទ្រ មានសញ្ញាសំគាល់ PLS ក្នុងសម័យកាល Permian (២៥១-២៩៩លានឆ្នាំ) នាស័ក Paleozoic ។[៣] នៅក្នុងរូងភ្នំនៃភ្នំទាក់ទ្រាំងពុំសូវឃើញមានឃើញផូស៊ីលទេ ខ្លះនៅសល់ស្នាកស្នាមតិចតួចជាពិសេស តែយើងបានជួបប្រទះនោះផ្នែកខាងក្រៅនៃភ្នំ និងទីតាំងដែលគេវាតយថ្មនៅភ្នំជាប់នោះដែលរកឃើញពពួកសត្វសមុទ្រមួយចំនួនដូចជា៖ ពពួកគ្រីណូអ៊ីត Crinoid (រូបលេខ៤) ស្ថិតនៅ សាខា (Phylum) Echinodermata ក្រុម (class) Crinoidea។[៤] ដែលសាខា Echinodermata មានក្រុមមួយចំនួនដែលស្ថិតនៅក្បែរពពួក Crinoidea មានផ្កាយសមុទ្រ និងពួកកាំប្រម៉ាសមុទ្រ យើងក៏ធ្លាប់បានចុះផ្សាយលើកមុនផងដែរ យើងបានជួនប្រទះពពួកគ្រីណូអ៊ីតនៅជើងភ្នំ ថ្មលេចចេញនៅតាមចំការនៃភ្នំមួយជាប់និងភ្នំទាក់ទ្រាំងដែលនៅមិនឆ្ងាយពីទីតាំងវាយថ្ម។ សត្វនេះក៏បានបន្តមករស់នៅដល់ពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា គ្រាន់តែ

---

[១] ២០២០, អនុក្រឹត្យលេខ០៦៧អនក្រ.បក

[២] ២០២០, របាយការណ៍សិក្សាផូស៊ីល ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

[៣] General Department of Mineral Resource, 2010, Geological Map of Cambodia

[៤] https://ams.com.kh/khmercivilization/detail/7547

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ជាពូជន៍ផ្សេងគ្នាតែប៉ុណ្ណោះ(រូបលេខ៥)។ ផូស៊ីលអាម៉ូណីតត្រូវបានជួបប្រទះនៅស្ថានីយផូស៊ីលសត្វសមុទ្រមួយចំនួនដូចជានៅភ្នំបាក់ ភ្នំជញ្ជាំង ភ្នំស្វាយ ភ្នំតូច ក្នុងខេត្តបន្ទាយមានជ័យ ដែលមានលក្ខណៈប្រហែលគ្នា នេះក៏អាចបង្ហាញអំពីទំនាក់ទំនងគ្នារវាងជិវិតដែលអាចស្ថិតក្នុងពេលប្រហាក់ប្រហែលគ្នា។

ផ្កាថ្មមួយប្រភេទរកឃើញនៅភ្នំមួយជាប់និងភ្នំទាក់ទ្រាំងក្នុងទីតាំងវាយថ្ម ដែលកប់ក្នុងទីតាំងនោះ។ ផ្កាថ្មនេះអាច អាចស្ថិតនៅក្នុង Colonial Rugosa Coral តែក៏មិនទាន់ដឹងថាវាជាប្រភេទមួយណាច្បាស់នៅឡើយទេ។ ពពួកនេះស្ថិតនៅសាខា Phylum Cnidaria, ថ្នាក់ (class) Anthozoa (coral), លំដាប់ Order Rugosa, colonial rugose coral (រូបលេខ៦ ទី៧)។[៥] ផ្កាថ្មនេះក៏មានលក្ខណៈប្រហាក់ប្រហែលនិងផ្កាថ្មមួយដែលឃើញនៅលើភ្នំបាក់ត្រង់កំពូលភ្នំ។

ផូស៊ីលមួយប្រភេទដែលមានរូបរៀងដូចជាបំពង់មានមុខកាត់ប្រមាណ៤ស.ម (រូបលេខ៨-៩) ដែលស្ថិតនៅក្នុង សាខា Phylum Porifera ( Spongy)។ យើងបានរកឃើញផូស៊ីលទាំងនេះនៅក្នុងបំណែកថ្មដែលគេវាយបំបែក។ Spongy មានបន្តរស់នៅរហូតដល់ពេលបច្ចុប្បន្ន វាមានលក្ខណៈប្រហាក់ប្រហែលផ្កាថ្ម តែរូបរាងកាយរបស់វា មិនសូវរឹង តន់ដូចអេប៉ុង។ ពួកនេះក៏បានរកឃើញនៅភ្នំបាក់ និងភ្នំស្វាយ ខេត្តបន្ទាយមានជ័យផងដែរ។

(រូបលេខ១០)ជាស្នាកស្នាមផូស៊ីលជាប់នៅក្នុងថ្មកំបោរ ពួកវាក៏អាចស្ថិតនៅក្នុងសាខា Phylum Porifera ( Spongy) ដែរ។ ពូកនេះក៏បានជួបប្រទះនៅស្ថានីយផូស៊ីលសត្វសមុទ្រភ្នំស្វាយដែលមានលក្ខណៈដូចគ្នា។[៦]

ថ្វីត្បិតតំបន់ភ្នំទាក់ទ្រាំងមានការរកឃើញសំណាកផូស៊ីលសត្វសមុទ្រមិនច្រើន អាចដោយសារការរលាយចូលក្នុងសាច់ថ្មពិបាកក្នុងការពិនិត្យមើល។ តែតាមរយៈភស្តុតាងផូស៊ីលមួយចំនួនដែលយើងបានជួនប្រទះ និងប្រៀបធៀបជាមួយស្ថានីយមួយចំនួនដូចជានៅភ្នំបាក់ ភ្នំស្វាយក្នុងខេត្តបន្ទាយមានជ័យ។ យើងអាចដឹងថាស្ថានីយនេះពិតជាមានទំនាក់ទំនងរវាងជីវិតសត្វដែលស្ថិតនៅក្នុងសម័យកាលជាមួយគ្នា។ ភ្នំទាក់ទ្រាំងមានអតីត

---

[៥] https://www.digitalatlasofancientlife.org/vc/cnidaria/anthozoa/rugosa/

[៦] https://ams.com.kh/khmercivilization/detail/7045

អត្ថបទដោយ៖ លឹម វណ្ណចន្ទ

កាលនៅក្នុងសមុទ្រ ក្នុងសម័យកាល Permian (២៥១-២៩៩លានឆ្នាំ) នាស័ក Paleozoic។ ទីតាំងនេះក៏គួរតែមានការសិក្សាបន្ថែមនៅលើភ្នំមួយចំនួនដែលនៅនោះ ។




រូបលេខ១




រូបលេខ២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៣



រូបលេខ៤ ពពួកគ្រីណូអ៊ីត

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ៥ ប្រភេទមួយនៃសត្វគ្រីណូអ៊ីត នៅសមុទ្រនៃប្រទេសកម្ពុជា ប្រភពរូប Amick



រូបលេខ៦

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៧



រូបលេខ២៨

អត្ថបទដោយ៖ លឹម វណ្ណាច័ន្ទ



រូបលេខ៩



រូបលេខ១០

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១១

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណចន្ទ